# បទអន្តរាគមន៍
## របស់
## បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ក្នុងឱកាសពិភាក្សា
## សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧
***រដ្ឋសភា, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦***

ខ្ញុំបាទសូមគោរព ៖

-សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់;

-សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់;

-ឯកឧត្តមបណ្ឌិតអនុប្រធានទី ២ នៃរដ្ឋសភា;

-សម្តេច, ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា, នៃរដ្ឋសភា និង អង្គរដ្ឋសភា ដ៏ឧត្តុង្គឧត្តម!

តាងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំបាទសូមសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា, គណៈអចិន្ត្រៃយ៍នៃរដ្ឋសភា, គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា និង អង្គរដ្ឋសភាទាំងមូល ដែលបានចាត់ការយ៉ាងរួសរាន់ និង អនុម័តដាក់ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧** ចូលក្នុងរបៀបវារៈរបស់ខ្លួន ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភានាថ្ងៃនេះ។ ជាមួយនេះ, ខ្ញុំបាទសូមសំដែងអំណរគុណដោយឡែកចំពោះ **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម (គណៈកម្មការទី ២) នៃរដ្ឋសភា ដែលបានរួសរាន់ដឹកនាំដំណើរការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាង-ច្បាប់នេះ ជាមួយសមាជិក សមាជិកា នៃគណៈកម្មការទី ២ និងដោយមានការចូលរួមពី

គណៈកម្មការទាំងអស់នៃរដ្ឋសភា ដើម្បីធ្វើឱ្យសេចក្តីព្រាងច្បាប់នេះឈានចូលដល់សម័យប្រជុំពេញអង្គរដ្ឋសភា ដូចដែលឯកឧត្តមប្រធានគណៈកម្មការទី ២ នៃរដ្ឋសភា បានធ្វើរបាយការណ៍ដ៏ក្បោះក្បាយជូនអង្គរដ្ឋសភាជ្រាបអម្បាញ់មិញនេះ។ អាស្រ័យដោយរាជរដ្ឋាភិបាលបានរៀបចំសេចក្តីថ្លែងហេតុពិស្តារមួយ គោរពជូន **សម្តេចចក្រីប្រធានរដ្ឋសភា** និងអង្គសភារួចហើយ ហើយ **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** ក្នុងនាមគណៈកម្មការទី២ នៃរដ្ឋសភាក៏បានរាយការណ៍លម្អិតបន្ថែមទៀតជូនអង្គរដ្ឋសភាអម្បាញ់មិញនេះហើយដែរ រួមទាំងអំពីមូលដ្ឋានគតិយុត្ត, ទិដ្ឋភាពរួម និងរចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់នេះផង, ដូច្នេះ នៅពេលនេះ ខ្ញុំបាទសូមអនុញ្ញាតធ្វើបទឧទ្ទេសនាមដោយសង្ខេបខ្លះដើម្បីចំណេញពេល។ យ៉ាងណាក៏ដោយ, ខ្ញុំបាទគោរពសុំការអធ្យាស្រ័យជាមុន ចំពោះករណីដែលខ្ញុំបាទអាចថ្លែងឡើងវិញ ក្នុងគោលដៅគូសបញ្ជាក់ ឬសង្កត់ធ្ងន់បន្ថែម ឬសម្រួចបន្ថែម នូវចំណុចមួយចំនួននៅក្នុងបទឧទ្ទេសនាមនេះ ដែលអាចជាន់គ្នានឹងអ្វីដែល **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** បានរាយការណ៍ជូនអង្គរដ្ឋសភាមុននេះ។

## I - **អំពីបរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០១៧**

នៅក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងទទួលផលពីសន្តិភាព, ឯកភាពទឹកដី, ឯកភាពជាតិ, ស្ថេរភាពនយោបាយ និងការអភិវឌ្ឍ ក៏ប៉ុន្តែសភាពការណ៍សេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយនៅលើសកលោក និងក្នុងតំបន់ បន្តជួបប្រឈមនឹងភាពមិនប្រាកដប្រជាមួយចំនួន, សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ត្រូវបានគិតគូររៀបចំឡើង ដើម្បីបង្ហាញអំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចគោលដៅនៃកម្មវិធីនយោបាយរបស់ខ្លួន ជាពិសេសសំដៅធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងប្រក្រតីភាពនៃជីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងបន្តទ្រទ្រង់ចលនការនៃការអភិវឌ្ឍ និងការកែទម្រង់សំខាន់ៗ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច និងធានាការបែងចែកផ្លែផ្កានៃកំណើននេះ ឱ្យបានកាន់តែមានសមធម៌ថែមទៀត។

ជារួម, កម្ពុជានៅតែអាចបន្តសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំនៅក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ ក៏ប៉ុន្តែ, ការរៀបចំថវិកាឆ្នាំ២០១៧ នេះ ស្ថិតក្នុងបរិការណ៍ដែលកម្ពុជាត្រូវប្រឈមនឹងហានិភ័យពីកត្តាខាងក្រៅ និងកត្តាខាងក្នុងមួយចំនួនដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា **ដូចដែលឯកឧត្តមប្រធានគណៈកម្មការទី ២** បានលើកឡើងរួចហើយ ហើយជាយថាហេតុក៏អាចធ្វើឱ្យប៉ះពាល់ដល់

ការប្រមូលចំណូលគ្រប់ប្រភេទផងដែរ ក្នុងពេលដែលរាជរដ្ឋាភិបាលក៏មានតម្រូវការបង្កើនចំណាយដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ និងតម្រូវការថ្មីៗដែលចាំបាច់ចៀសមិនបាន។

នៅក្នុងស្ថានភាពនេះ, យុទ្ធសាស្ត្រនៃការរៀបចំថវិកាឆ្នាំ ២០១៧ គឺផ្តោតលើការរក្សាចីរភាពនៃកំណើនចំណូល ដែលរាជរដ្ឋាភិបាលខិតខំប្រឹងប្រែងសម្រេចលទ្ធផលល្អ ក្នុងរយៈ-ពេលកន្លងទៅ ដើម្បីធានាបាននូវការបន្តជំរុញដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល, ការជំរុញការកែទម្រង់រដ្ឋបាលសាធារណៈ, ការសម្រួលធុរកិច្ច និងការលើកកម្ពស់ភាពប្រកួតប្រជែង, ការកែលម្អសេវាសាធារណៈសម្រាប់ប្រជា-ពលរដ្ឋ និងការបង្កើនការវិនិយោគសាធារណៈ ដើម្បីបំពេញដល់ការថមថយនៃការវិនិយោគឯកជនផង និងលើកកម្ពស់បន្ថែមនូវផលិតភាពនិងភាពទាក់ទាញរបស់កម្ពុជាសម្រាប់វិនិយោ-គិនផង។

ជារួម, គោលនយោបាយនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៧ គឺជាគោល-នយោបាយវិត្ថារកម្មថវិកាប្រយ័ត្នប្រយែង ដើម្បីថែរក្សានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទ្រទ្រង់កំណើនក្នុងរយៈពេលខ្លី ព្រមទាំងបង្កើតលក្ខខណ្ឌចាំបាច់ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងរយៈ-ពេលមធ្យម និងវែង ជាពិសេស ដើម្បីបង្ហាញអំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនីតិ-កាលទី ៥ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ ប្រកបដោយគតិបណ្ឌិត របស់សម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** ឆ្ពោះទៅរកការសម្រេចគោលដៅសំខាន់ៗបន្ថែមទៀតនៃកម្មវិធីនយោបាយរបស់ខ្លួន សំដៅឆ្លើយតបទៅនឹងឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត ក៏ដូចជាសំដៅពន្លឿនការអនុវត្តកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗ, ពិសេស បង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល និងធានាឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី ៤, ដែលជាដំណើរការនៃការអនុវត្តនូវលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន, ឱ្យប្រព្រឹត្តទៅដោយរលូន មានសណ្តាប់ធ្នាប់ និងប្រកបដោយតម្លាភាព, ទន្ទឹមនឹងការធានារក្សាការពារនូវសុខសន្តិភាពដែលសម្រេចបានមកដោយលំបាក ឱ្យស្ថិតស្ថេរគង់វង្សចីរកាល។

## II - អំពីគោលការណ៍នៃការរៀបចំថវិកាឆ្នាំ ២០១៧

ដើម្បីគោលដៅខាងលើ, ក្របខណ្ឌថវិកាឆ្នាំ ២០១៧ ត្រូវបានរៀបចំឡើងដោយឈរលើ **គោលការណ៍សំខាន់ៗ** ជាពិសេស ដូចខាងក្រោម ៖

***១/-ការពិនិត្យ និងផ្ទៀងផ្ទាត់ប្រភពចំណូល:*** ដើម្បីបង្កើនចំណូលថវិកាឱ្យអស់លទ្ធភាព ហើយផ្អែកលើមូលដ្ឋាននេះ គិតគូររៀបចំចំណាយឱ្យកាន់តែចំទិសដៅគោលនយោបាយ និង សន្សំសំចៃខ្ពស់។

***២/-ការកំណត់លំដាប់អាទិភាព:*** តាមរយៈការបន្តនូវភាពម៉ឺងម៉ាត់ និងការសម្រួចលើការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ ដោយផ្ដោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិ-ភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងទៅលើកម្មវិធី/សកម្មភាពចាំបាច់ជាអាទិភាពរបស់ក្រសួង-ស្ថាប័ន។ ក្នុងន័យនេះ, កំណើនថវិកាត្រូវបានផ្ដល់អាទិភាពជាសំខាន់ទៅលើកម្មវិធី/អនុកម្ម-វិធី/សកម្មភាពណាដែលអាចរំពឹងថានឹងសម្រេចបានលទ្ធផលជាក់លាក់ ជាពិសេស សកម្ម-ភាពណា ដែលអាចសម្រេចបានលទ្ធផលច្រើនដោយចាយថវិកាតិច។ លើសពីនេះ, ក្នុងករណីដែលលទ្ធភាពថវិកានៅតែមិនអាចឆ្លើយតប ទៅនឹងតម្រូវការជាអាទិភាពថ្មីរបស់ក្រសួង-ស្ថាប័ន, មុខចំណាយជាប្រចាំមួយចំនួន ក៏ត្រូវបានយកមកពិនិត្យធ្វើអាទិភាពឡើងវិញដែរ។

***៣/-ការយកចិត្តទុកដាក់លើមនុស្ស:*** ទន្ទឹមនឹងបន្តបង្កើនប្រាក់បៀវត្សអប្បរមា ជូនមន្ត្រីរាជការគ្រប់ប្រភេទ ឆ្ពោះទៅច្រើនជាង ១ លានរៀល នៅឆ្នាំ ២០១៨, ថវិកាឆ្នាំ ២០១៧ បានដាក់ចេញថែមទៀត នូវវិធានការពន្ធដារពាក់ព័ន្ធនឹងការសម្រួលកម្រិតជាប់ពន្ធនៃប្រាក់-បៀវត្ស ដើម្បីផ្ដល់ការលើកទឹកចិត្ត និងរួមចំណែកលើកកម្ពស់ជីវភាពដល់មន្ត្រីរាជការពិសេស គ្រូបង្រៀន និងគ្រូពេទ្យ ព្រមទាំងកម្មករនិយោជិតដែលមានបៀវត្សទាប។ លើសពីនេះ, ថវិកាឆ្នាំ ២០១៧ ក៏បានផ្ដល់អាទិភាពដល់ការកសាង និងពង្រឹងធនធានមនុស្ស និងផ្ដល់ការយកចិត្តទុកដាក់ដល់ការឧបត្ថម្ភគាំទ្រចំពោះមនុស្ស ដែលត្រូវទទួលខុសត្រូវក្នុងការ-អនុវត្តការងារផ្ទាល់ ក៏ដូចជាការពង្រឹងគុណភាពសេវាសាធារណៈ ដែលផ្ដល់ប្រយោជន៍ផ្ទាល់ដល់ប្រជាជនទូទៅ។

***៤/-ការកំណត់តម្លៃជាក់ស្ដែងនៃកម្មវិធី/សកម្មភាព:*** ដោយគិតគូរឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ, បរិមាណ, និងគុណភាព ក្នុងការអនុវត្តកម្មវិធី/សកម្មភាពតាំងពីក្នុងដំណាក់កាលនៃការរៀបចំថវិកា ចៀសវាងការលើកគម្រោងចំណាយមានលក្ខណៈចេបាលៗ និងក្នុងលក្ខណៈប្រថុចញ៉ុច ដែលធ្វើឱ្យការវិភាជថវិកាមិនសូវមានប្រសិទ្ធភាព ហើយខ្វះខាតថវិកានៅពេលអនុវត្ត។

***៥/-ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត, ពិសេសនៅក្នុងវិស័យអាទិភាព ពោលគឺ វិស័យ-អប់រំ និង សុខាភិបាល,*** ដោយបង្កើនការផ្ទេរថវិកាឱ្យទៅដល់អង្គភាពអនុវត្តការងារផ្ទាល់

ដែលនៅក្រោមឱវាទក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល ឬនៅតាមមូលដ្ឋានក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពចំណាយ ជាពិសេស ធានាបាននូវភាពទាន់ពេលវេលា និងការទទួល-ខុសត្រូវច្បាស់លាស់ នៅក្នុងការគ្រប់គ្រង និងចាត់ចែងអនុវត្តថវិកា។

*៦/-ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា:* តាមរយៈវិធានការផ្សារភ្ជាប់ការវិភាជថវិកា ទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ជាពិសេស ផ្តល់អាទិភាពលើចំណាយមិនមែនបុគ្គលិកដល់ក្រសួង-ស្ថាប័ន ដែលកៀរគរចំណូលបានដោយការខិតខំអនុវត្តសកម្ម-ភាពប្រមូលចំណូល ហើយបានបង់ចំណូលមួយភាគធំចូលថវិការដ្ឋ, ទន្ទឹមនឹងការរឹតត្បិតលើការស្នើសុំបង្កើនថវិកា ចំពោះក្រសួង-ស្ថាប័នដែលការប្រមូលចំណូលមិនអាចសម្រេចបានលទ្ធផលសមស្របតាមសក្តានុពលជាក់ស្តែង ឬដែលមានទំហំចំណែកប្រាក់រង្វាន់ធំ។

*៧/-ការរក្សាតុល្យភាពថវិកា:* ទោះបីជាស្ថិតក្រោមសម្ពាធនៃតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់ ជាពិសេស សម្ពាធនៃចំណាយបន្ទុកបុគ្គលិក ចំណាយចរន្តមិនមែនបន្ទុកបុគ្គលិកដែលកើតឡើងថ្មីៗ ព្រមទាំងចំណាយវិនិយោគដើម្បីជំរុញការអភិវឌ្ឍ ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន, ហើយនៅក្នុងពេលដំណាលគ្នានេះការប្រមូលចំណូលក៏នៅបន្តជួបបញ្ហាប្រឈម និងហានិភ័យមួយចំនួនធំក៏ដោយ, ការរៀបចំថវិកាឆ្នាំ ២០១៧ ត្រូវបានធ្វើលើមូលដ្ឋាននៃការធានាឱ្យបាននូវតុល្យភាព ហើយទន្ទឹមនឹងនេះ ក៏មានការត្រៀមបម្រុងសម្រាប់សេចក្តីត្រូវការមិនបានគ្រោងទុក និងសម្រាប់ការធ្វើអន្តរាគមន៍ ជាយថាហេតុរបស់រាជរដ្ឋាភិបាលក្នុងវិស័យសេដ្ឋកិច្ច និងសង្គមផងដែរ។

## III - អំពីក្របខណ្ឌថវិកាឆ្នាំ ២០១៧

ក្របខណ្ឌថវិកាឆ្នាំ ២០១៧ ត្រូវបានរៀបចំដោយឈរលើគោលការណ៍ដូចបានជម្រាបខាងលើ ក៏ដូចជាក្នុងក្របខណ្ឌនៃកំណើនសេដ្ឋកិច្ចដែលត្រូវបានគ្រោងក្នុងរង្វង់ ៧% ព្រមជាមួយនឹងសេណារីយ៉ូចំណូលដែលមានលក្ខណៈសុទិដ្ឋិនិយម និងដោយឈរលើមូល-ដ្ឋាននៃលទ្ធផលល្អប្រសើរនៃការអនុវត្តចំណូលសារពើពន្ធក្នុងរយៈពេល ៣ ឆ្នាំ ចុងក្រោយ នេះ។

ជារួម, ក្របខណ្ឌថវិកាឆ្នាំ ២០១៧ ត្រូវបានកំណត់ដូចតទៅ៖

**១-ចំណូលក្នុងប្រទេស<u>ថវិការដ្ឋ</u> ឬ ហៅថាចំណូលក្នុងប្រទេស<u>ថវិកាជាតិ</u>** ត្រូវបានគ្រោងចំនួន ១៦ ៦១៧ ៤២៨ លានរៀល, សមមូលប្រមាណ ៤ ១០៣ លានដុល្លារអាមេរិក, ត្រូវជា ១៨,៦៦% នៃ ផសស និងមានកំណើន ១៥,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៦។ ក្រប-ខណ្ឌថវិកាឆ្នាំ ២០១៧ មានគោលដៅបង្កើន**ចំណូលចរន្តថវិការដ្ឋ**ឱ្យបានស្មើនឹង ១៨,៥% នៃ ផសស ដែលមានកំណើនចំនួន **០,៧៩** ពិន្ទុភាគរយ នៃ ផសស ធៀបនឹងច្បាប់ឆ្នាំ

២០១៦ **ពេលគឺនឹងសម្រេចបានលើសគោលដៅ** ដែលបានដាក់នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ ២០១៤-២០១៨ ដែលបានកំណត់ថា រាជរដ្ឋាភិបាលត្រូវប្រមូលចំណូលចរន្តថវិការដ្ឋឱ្យបានកើនស្មើនឹង **០,៥០ ពិន្ទុភាគរយ** នៃ ផសស ជាប្រចាំឆ្នាំក្នុងរយៈពេលមធ្យម។ **ត្រង់នេះ ខ្ញុំបាទសូមសង្កត់ធ្ងន់បន្ថែមថា ការសម្រេចបាននូវកំណើនចំណូលក្នុងរយៈពេល បី ឆ្នាំចុងក្រោយនេះ គឺជាកំណើនមួយខ្ពស់ មិនធ្លាប់មាននៅក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយ ហើយសូម្បីតែមូលធិនិរូបិយវត្ថុអន្តរជាតិ ក៏បានផ្តល់ការវាយតម្លៃខ្ពស់លើសមិទ្ធផលនៃការខិតខំប្រឹងប្រែងនេះផងដែរថា មិនធ្លាប់មានពីមុនមកនៅក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់។** ជាក់ស្តែង, ចំណូលសារពើពន្ធកម្ពុជា ដែលនៅពេលនេះ មានទំហំក្នុងរង្វង់ ១៦% នៃ ផសស ដែលបានកើនឡើងពីកម្រិតប្រមាណ ១២,៧% នៃ ផសស ឆ្នាំ ២០១៣ គឺឈានដល់កម្រិតប្រដំប្រសងនឹងទំហំនៃចំណូលសារពើពន្ធរបស់បណ្តាប្រទេសក្នុងតំបន់ហើយ។ **យ៉ាងណាមិញ, នេះគឺជាផលផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងអនុវត្តក្នុងធន្ទះប្តូរផ្តាច់ឥតងាករេនូវវិធានការមុតស្រួចទាំងឡាយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលបានចាប់ផ្តើមតាំងពីនីតិកាលមុនៗមក នៅក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត ក៏ដូចជាការគាំទ្រ និងត្រួតពិនិត្យតាមដានជាប់ជាប្រចាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

២-**ចំណាយសរុប**<u>ថវិការដ្ឋ</u> ឬ **ចំណាយសរុប**<u>ថវិកាជាតិ</u> ត្រូវបានគ្រោងចំនួន ២១ ១៥១ ៩៨៥ លានរៀល, សមមូលប្រមាណ ៥ ២២៣ លានដុល្លារអាមេរិក, ត្រូវជា ២៣,៧៦% នៃ ផសស និងមានកំណើន ១៥,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៦, ក្នុងនោះ ចំណាយចរន្តថវិការដ្ឋត្រូវបានគ្រោងចំនួន ១៣ ៧៩៩ ០៧៩ លានរៀល, សមមូលប្រមាណ ៣ ៤០៧ លានដុល្លារអាមេរិក, ត្រូវជា ១៥,៥% នៃ ផសស និងមានកំណើន ១៦,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៦ ។ ត្រង់នេះ ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា គម្រោង<u>**ចំណាយបន្ទុកបុគ្គលិក**</u>សរុបនៃថវិការដ្ឋឆ្នាំ ២០១៧ នឹងមានទំហំ ៧ ១៣៤ ៣៨៨ លានរៀល, សមមូលប្រមាណ ១ ៧៦២ លានដុល្លារអាមេរិក, ត្រូវជា **៨,០១% នៃ ផសស** ឬស្មើនឹង **៥១,៧%** នៃចំណាយចរន្តថវិការដ្ឋ ដែលឆ្លុះបញ្ចាំងអំពីការផ្តល់អាទិភាពលើមនុស្សនៃគោលនយោបាយថវិការបស់រាជរដ្ឋាភិបាល។

## IV - អំពីគម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិ

### ទី១- អំពីគម្រោងចំណូលថវិកា<u>ថ្នាក់ជាតិ</u>

ថវិកាឆ្នាំ ២០១៧ មានគោលដៅបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យមានទំហំស្មើនឹង ១៥ ៦៤៩ ៩០០ លានរៀល, សមមូលប្រមាណ ៣ ៨៦៤ លានដុល្លារអាមេរិក, ត្រូវជា ១៧,៥៨% នៃ ផសស គឺមានកំណើន ១៥,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៦។ ក្នុងក្របខណ្ឌនេះ, **ឯកឧត្តមប្រធានគណៈកម្មការទី២** បានរាយការណ៍គោរពជូន **សម្តេចចក្រីប្រធានរដ្ឋសភា** និងអង្គសភា ជ្រាបអម្បាញ់មិញនេះរួចហើយ អំពីគោលដៅសម្រាប់ចំណូលចរន្ត, ទាំងគោលដៅចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ, ព្រមទាំងគោលដៅចំណូលមូលធន, ទាំងចំណូលមូលធនក្នុងប្រទេស និង ចំណូលមូលធនក្រៅប្រទេស។ ដូច្នេះ, ដើម្បីបានចំណេញពេលវេលាខ្លះ, ខ្ញុំបាទសូមការអនុញ្ញាតមិនអធិប្បាយនូវចំណុចទាំងអស់នោះ សាជាថ្មីឡើងវិញទេ ដោយគ្រាន់តែសុំគូសរំលេចបន្ថែមថា ដើម្បីរួមចំណែកសម្រេចគោលដៅចំណូលសារពើពន្ធដែលបានដាក់ចេញនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និង អគ្គនាយកដ្ឋានពន្ធដារ, ដែលជាអង្គភាពប្រមូលចំណូលធំពីរស្ថិតក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ទាល់, ត្រូវខិតខំសម្រេចឱ្យបានតាមគោលដៅដែលបានគ្រោង ដូចខាងក្រោម៖

- ចំណូលគយនិងរដ្ឋាករ ត្រូវបានគ្រោងចំនួន ៧ ៣០៩ ០០០ លានរៀល, សមមូលប្រមាណ ១ ៨០៥ លានដុល្លារអាមេរិក, ត្រូវជា ៨,២១% នៃ ផសស គឺមានកំណើន ៩,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៦;
- ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន ៥ ៩០០ ១០០ លានរៀល, សមមូលប្រមាណ ១ ៤៥៧ លានដុល្លារអាមេរិក, ត្រូវជា ៦,៦៣% នៃ ផសស គឺមានកំណើន ២០,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៦។

ទន្ទឹមនេះ, គួរកត់សម្គាល់ថា ចំពោះ **ចំណូលមិនមែនសារពើពន្ធ** ត្រូវបានគ្រោងចំនួន ២ ២៩២ ៣៦៩ លានរៀល, សមមូលប្រមាណ ៥៦៦ លានដុល្លារអាមេរិក, មានកំណើន ២៣,៨% ធៀបនឹងច្បាប់ឆ្នាំ ២០១៦ ដោយសារប្រភពធំៗមួយចំនួន ក្នុងនេះរួមមាន **ចំណូល-ពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ (អនុវត្តដោយគ្រឹះស្ថានអង្គរ) ចំនួន ៣៩៤ ៦៣៩ លានរៀល,** សមមូលប្រមាណ ៩៧ លានដុល្លារអាមេរិក, ជាចំណូលដែលត្រូវបានកត់ត្រាចូលថវិកាជាតិទាំងស្រុង។

## ទី២- អំពីគម្រោងចំណាយថវិកាថ្នាក់ជាតិ

### ក. អំពីទិដ្ឋភាពរួមនៃចំណាយចរន្តថវិកាថ្នាក់ជាតិ

ដូចឯក**ឧត្តមប្រធានគណៈកម្មការទី២** បានរាយការណ៍រួចហើយដែរ, ថវិកាថ្នាក់ជាតិឆ្នាំ ២០១៧ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយចរន្ត ឱ្យស្ថិតក្នុងកម្រិតចំនួន ១៣ ០៥០ ៦៨៦

លានរៀល, សមមូលប្រមាណ ៣ ២២២ លានដុល្លារអាមេរិក, ត្រូវជា ១៤,៦៦% នៃ ផសស គឺមានកំណើន ១៧,០% ធៀបនឹងច្បាប់ឆ្នាំ ២០១៦ ដែលក្នុងនោះ ៖

**ក-១-<u>ចំណាយលើបន្ទុកបុគ្គលិក:</u>** មានកំណើន ២០,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៦, ត្រូវជា ៧,៦៤% នៃ ផសស និង មានសមាមាត្រស្មើនឹង ៥២,១៤% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ។ ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា អាទិភាពនៃចំណាយនេះ ត្រូវបានផ្តោតលើការគ្រោងសម្រាប់: (១)-**ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា ១២,០% ដោយអនុវត្តចាប់ពី ខែ មករា ឆ្នាំ ២០១៧,** (២)-**ការដំឡើងប្រាក់បំណាច់មុខងារដែលនឹងត្រូវអនុវត្តចាប់ពីខែ មេសា ឆ្នាំ ២០១៧** និង (៣)-**ការដំឡើងប្រាក់ឧបត្ថម្ភប្រពន្ធ-កូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដោយផ្តល់ឱ្យកូនម្នាក់ចំនួន ១០ ០០០ រៀល ក្នុងមួយខែ និងប្រពន្ធចំនួន ១៥ ០០០ រៀល ក្នុងមួយខែ គិតចាប់ពីខែមករា ឆ្នាំ២០១៧។** តាមរយៈវិធានការនេះ ស្ថានភាព បៀវត្សអប្បបរមា របស់មន្ត្រីរាជការគ្រប់ប្រភេទ នឹងត្រូវបានផ្លាស់ប្តូរដូចតទៅ៖

**ទី១. សម្រាប់មន្ត្រីរាជការស៊ីវិល៖**

-បៀវត្សមន្ត្រីរាជការស៊ីវិល ដែលមិនមែនជាគ្រូបង្រៀន ឬគ្រូពេទ្យ នឹងត្រូវបានដំឡើងពីជាង ៧០ ម៉ឺនរៀល ដល់ប្រមាណជាង ៨៥ ម៉ឺនរៀល;

-បៀវត្សគ្រូបង្រៀន និងគ្រូពេទ្យ នឹងត្រូវបានដំឡើងពីជាង ៨០ ម៉ឺនរៀល ដល់ប្រមាណជាង ៩៥ ម៉ឺនរៀល;

**ទី២. សម្រាប់កងកម្លាំងប្រដាប់អាវុធ៖**

-បៀវត្សនគរបាល (ពលបាលត្រី) នឹងត្រូវបានដំឡើងពីជាង ៧៨ ម៉ឺនរៀល ដល់ប្រមាណជិត ៩៤ ម៉ឺនរៀល (គិតបញ្ចូលរបបអង្គរ);

-បៀវត្សយោធិន (ពលទោ) នឹងត្រូវបានដំឡើងពីជាង ៧៣ ម៉ឺនរៀល ដល់ប្រមាណជាង ៨៨ ម៉ឺនរៀល (គិតបញ្ចូលរបបអង្គរ);

**ទី៣.** ជាមួយគ្នានេះដែរ ប្រាក់ឧបត្ថម្ភមន្ត្រីជាប់កិច្ចសន្យា នឹងត្រូវបានដំឡើងពី ៤០ ម៉ឺនរៀល ដល់ ៥០ ម៉ឺនរៀល ចាប់ពីខែ មករា ឆ្នាំ ២០១៧ ។ ចំពោះនិវត្តជន, ទាំងជាមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ, ក៏មានការគ្រោងថវិកាប្រមាណ ៤៤ ប៊ីលានរៀលផងដែរ សម្រាប់ដំឡើងសោធនកម្រិតទាបបំផុតឱ្យឡើងដល់ ៤២ ម៉ឺនរៀល ក្នុងមួយខែ ដើម្បីឈានឱ្យដល់ ៤៨ ម៉ឺនរៀល ក្នុង ១ ខែ នៅក្នុងឆ្នាំ ២០១៨។]

**ក-២-<u>ចំណាយក្រៅបន្ទុកបុគ្គលិកៈ</u>** មានកំណើនត្រឹមតែ ១៣,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៦ ត្រូវជា ៧,០២% នៃ ផសស និង មានសមាមាត្រស្មើនឹង ៤៧,៨៦% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ។

### ខ. <u>អំពីទិដ្ឋភាពនៃការវិភាជន៍តាមវិស័យនៃថវិកាថ្នាក់ជាតិ</u>

ជារួម,ចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ឆ្នាំ ២០១៧ ត្រូវបានវិភាជន៍ដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់ រួមទាំងការអនុវត្តនូវគោលការណ៍ថ្មីមួយចំនួន ទៅតាមវិស័យនីមួយៗ ស្របតាមគោលការណ៍នៃការរៀបចំថវិកា ដូចបានគូសបញ្ជាក់នៅក្នុងសេចក្ដីថ្លែង-ហេតុ។ ទន្ទឹមនឹងនេះ, អាទិភាពចំណាយសំខាន់ៗ តាមវិស័យនីមួយៗ ក៏មានគូសបញ្ជាក់ពិស្ដារនៅក្នុងខ្លឹមសារនៃអត្ថបទសេចក្ដីថ្លែងហេតុរបស់រាជរដ្ឋាភិបាល ហើយឯកឧត្ដមប្រធានគណៈកម្មការទី២ ក៏បានលើកឡើងបន្ថែមទៀតអម្បាញ់មិញនេះផងដែរ។ ដូច្នេះ ដើម្បីចំណេញពេលបានថែមទៀត ខ្ញុំបាទសូមមិនអធិប្បាយលម្អិតឡើងវិញទេ, ក៏ប៉ុន្តែខ្ញុំបាទសូមធ្វើការគូសរំលេចទិដ្ឋភាពសំខាន់ជាគោលមួយចំនួនដូចខាងក្រោម ៖

**ទី១. វិស័យសង្គមកិច្ចនៅតែត្រូវបានចាត់ទុកជាវិស័យអាទិភាពទី១** ដោយក្នុងនោះការយកចិត្តទុកដាក់ត្រូវបានផ្ដោតជាពិសេសលើក្រសួងអាទិភាពចំនួន ៣ គឺ ក្រសួងអប់រំ យុវជននិងកីឡា, ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង ក្រសួងសុខាភិបាល ។ **ជានិន្នាការ, ទំហំចំណាយចរន្តរបស់វិស័យនេះមានការកើនឡើងខ្លាំងជាងគេ,** ហើយត្រូវបានគ្រោងចំនួន ៤ ៨៣៦ ៥៩៨ លានរៀល, សមមូលប្រមាណ ១ ១៩៤ លានដុល្លារអាមេរិក ពោលគឺ មានកំណើន ១២,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៦, ត្រូវជា ៥,៤៣% នៃ ផសស និង មានសមាមាត្រស្មើនឹង ៣៧,១% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ។ **លើសពីនេះ, បើគិតពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧ ចំណាយចរន្តវិស័យសង្គមកិច្ច បានកើនឡើងពីទំហំ ៤,២៥% នៃ ផសស រហូតដល់ទៅ ៥,៤៣% នៃ ផសស, មានន័យថាបានកើន ១,១៨% ពិន្ទុភាគរយ។ អាទិភាពចំណាយនៃវិស័យនេះ** ត្រូវបានផ្ដោតទៅលើ៖ ការបន្តគាំទ្រ ដល់ការពង្រីកការទទួលបានសេវាអប់រំ និងការលើកកម្ពស់គុណភាពអប់រំ ព្រមទាំងការអប់រំកាយ និងកីឡា ជាពិសេសការបន្តផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ; ការបង្កើនថវិកាដំណើរការសាលារៀន; ការបន្តពង្រីកសាលារៀនជំនាន់ថ្មី និងការកសាងសាលារៀន; ការអភិវឌ្ឍជំនាញដែលឆ្លើយ-តបនឹងតម្រូវការទីផ្សារ ជាពិសេសនៅក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងការអភិវឌ្ឍវិស័យ ការងារ; ការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល និង ការពង្រីកការទទួលបានសេវា សុខាភិបាល ពិសេសសម្រាប់ប្រជាជនក្រីក្រ, ក្រុមជនងាយរងគ្រោះ, ស្ត្រី និងកុមារ តាមរយៈការបន្តគាំទ្រ

ដល់កម្មវិធីមូលនិធិសមធម៌, ការបន្តបង្កើនកញ្ចប់ថវិកាប្រតិបត្តិការជូនដល់មន្ទីរ-ពេទ្យបង្អែក និងមណ្ឌលសុខភាព; និងការបង្កើនការគាំទ្រដល់ប្រតិបត្តិការរបស់មន្ទីរពេទ្យ គន្ធបុប្ផាជាបណ្តើរៗ; ក៏ដូចជាការបន្តគាំទ្រដល់កិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ជាដើម។]

**ទី២. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** [ត្រូវបានគ្រោងចំនួន ៣ ៣៣៨ ៤០០ លានរៀល, សមមូលប្រមាណ ៨២៤ លានដុល្លារអាមេរិក, មានកំណើន ២០,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៦, ត្រូវជា ៣,៧៥% នៃ ផសស និងមានសមាមាត្រស្មើនឹង ២៥,៦% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ] ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិកមានចំនួនរហូតទៅដល់ ៧៧,៨% ដែលមានកំណើន ២៦,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៦,** ចំណែកឯ **ចំណាយមិនមែនបន្ទុកបុគ្គលិក មានតែត្រឹម ២២,២% នៃចំណាយសរុបរបស់វិស័យ ហើយមានកំណើនតែ ២,៥% ប៉ុណ្ណោះ ធៀបនឹងច្បាប់ឆ្នាំ ២០១៦។** ជានិន្នាការ, **បើគិតពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧, ចំណាយចរន្តវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សា-ធារណៈបានកើនពីទំហំ ២,៩២% នៃ ផសស ដល់ទំហំត្រឹម ៣,៧៥% នៃ ផសស ប៉ុណ្ណោះ។** [**អាទិភាពចំណាយនៃវិស័យនេះ** ត្រូវបានផ្តោតទៅលើ ៖ ការលើកកម្ពស់ជីវភាពរស់នៅរបស់កងកម្លាំងប្រដាប់អាវុធ, ការផ្គត់ផ្គង់ឯកសណ្ឋាន និងសម្លៀកបំពាក់, ការផ្តល់ការលើកទឹកចិត្តដល់នគរបាលចរាចរណ៍ និងនគរបាលទេសចរណ៍, ការបន្តផលិតលិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, ការបំពាក់ប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យព្រំដែន, ការបន្តគាំទ្រដល់ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព, ការបង្កើនថវិកាសម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, សាលាជំរះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋ-បាលតុលាការ ជាដើម។]

**ទី៣. វិស័យរដ្ឋបាលទូទៅ** [ត្រូវបានគ្រោងចំនួន ១ ៩៨៦ ៩៤២ លានរៀល, សមមូលប្រមាណ ៤៩១ លានដុល្លារអាមេរិក, មានកំណើន ២៤៤,% ធៀបនឹងច្បាប់ឆ្នាំ ២០១៦, ត្រូវជា ២,២៣% នៃ ផសស និង មានសមាមាត្រស្មើនឹង ១៥,២% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ។] **បើគិតពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧, ចំណាយចរន្តវិស័យរដ្ឋបាលទូទៅ បានកើនពីទំហំ ១,៧៧% នៃ ផសស ដល់ទំហំ ២,២៣% នៃ ផសស។** [ក្នុងនោះ, សម្រាប់ឆ្នាំ ២០១៧, កញ្ចប់ថវិការបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានកំណើនរហូតដល់ ៥៧,៦% ធៀបច្បាប់ឆ្នាំ ២០១៦ សម្រាប់ការចុះឈ្មោះ, ពិនិត្យបញ្ជីឈ្មោះ និងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ព្រមទាំងសម្រាប់ការចុះឈ្មោះជ្រើសរើសតំណាងរាស្ត្រឆ្នាំ ២០១៨។

លើសពីនេះ, អាទិភាពចំណាយនៃវិស័យនេះ ក៏ត្រូវបានផ្ដោតផងដែរទៅលើ៖ ការបន្តគាំទ្រដល់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការបន្តជំរុញការចុះបញ្ជី និង ការ-ផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លី, ទាំងដីរដ្ឋ, ដីឯកជន និងដីសហគមន៍ជនជាតិដើមភាគតិច, ព្រមទាំងការបង្កើនប្រសិទ្ធភាពនៃកិច្ចការការទូត តាមរយៈការបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មន្ត្រីការទូតដែលកំពុងបំពេញភារកិច្ចនៅក្រៅប្រទេស ក៏ដូចជាការបន្តគាំទ្រដល់កិច្ចការពារ និងជួយសង្គ្រោះពលករខ្មែរដែលធ្វើការនៅក្រៅប្រទេស ជាពិសេស ស្ត្រីខ្មែរដែលត្រូវរងគ្រោះដោយការឆបោក និងការជួញដូរផ្លូវភេទ ជាដើម។]

**ទី៤. វិស័យសេដ្ឋកិច្ច** [ត្រូវបានគ្រោងចំនួន ១ ៣០៦ ៣៦៧ លានរៀល, សមមូលប្រមាណ ៣២៣ លានដុល្លារអាមេរិក, មានកំណើន ១៣,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៦, ត្រូវជា ១,៤១% នៃ ផសស និង មានសមាមាត្រស្មើនឹង ១០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ។ **បើគិតពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧, ចំណាយចរន្តវិស័យសេដ្ឋកិច្ច បានកើនពីទំហំ ០,៨៧% នៃ ផសស ដល់ទំហំ ១,៤៧% នៃ ផសស។**] ត្រង់នេះ ខ្ញុំបាទសូមគូសបញ្ជាក់ផងដែរថា ទោះបីជាក្រសួងសំខាន់ៗនៅក្នុងវិស័យសេដ្ឋកិច្ចនេះ មិនបានទទួលនូវកំណើនចំណាយចរន្តថវិកាថ្នាក់ជាតិច្រើននិងនៅមានទំហំតូចក្ដី, តែក្រសួងសំខាន់ៗទាំងនេះ ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, និង ក្រសួងសាធារណការនិងដឹកជញ្ជូន គឺជាស្ថាប័នដែលបានស្រូបយកចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេស រហូតទៅដល់ជាង ៧០% សម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវ ស្ពាន និងប្រព័ន្ធធារាសាស្ត្រ ជាដើម ។

## ខ- អំពីគម្រោងចំណាយមូលធនថវិកាថ្នាក់ជាតិ

**ចំណាយមូលធនថ្នាក់ជាតិត្រូវបានគ្រោងចំនួន ៧ ១៣៣ ៧៧១ លានរៀល, សមមូលប្រមាណ ១ ៧៦១ លានដុល្លារអាមេរិក, មានកំណើន ១៣,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៦, ត្រូវជា ៨,០% នៃ ផសស** ដែលក្នុងនោះ ៖

- គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ មានកំណើន ១៣,៤% ធៀបនឹងច្បាប់ឆ្នាំ២០១៦ ហើយត្រូវជា ២,៤៥% នៃ ផសស ។ **គួរគូសបញ្ជាក់ផងដែរថាការកើនឡើងនៃចំណាយវិនិយោគដោយថវិកាជាតិនេះ គឺជាការឆ្លុះបញ្ចាំងពីការ-កើនឡើងនៃសមត្ថភាព និងឯករាជ្យភាពខាងថវិការបស់កម្ពុជា** នេះម្យ៉ាង, ម្យ៉ាងទៀត ក៏ជាការខិតខំរបស់របស់រាជរដ្ឋាភិបាល ក្នុងការបង្វែរទុនវិនិយោគសាធារណៈកាន់តែច្រើនដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច និងបង្កើតការងារក្នុងស្រុកផងដែរ។

- គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស មានកំណើន១០,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៦ ហើយ ត្រូវជា ៤,៨១% នៃ ផសស ។ ជាក់ស្តែង, រាជរដ្ឋាភិបាល បន្តគ្រោងកំណត់ពិដានក្នុងការខ្ចីសម្រាប់ឆ្នាំ ២០១៧ ក្នុងរង្វង់ ៧០០ លានអេសឌីអ៊ែរ ដូចឆ្នាំ ២០១៦ នេះដដែល ស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨។

ជារួម, ចំណាយមូលធនរបស់រាជរដ្ឋាភិបាល មានគោលដៅផ្តល់ហិរញ្ញប្បទានដល់គម្រោង/កម្មវិធី ក្នុងវិស័យអាទិភាព **ដោយផ្តោតទៅលើការទ្រទ្រង់កំណើនសេដ្ឋកិច្ច ព្រមទាំងការលើកកម្ពស់ភាពប្រកួតប្រជែង និង ផលិតភាពសេដ្ឋកិច្ចជាតិ** ដូចដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ និង កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៧-២០១៩។

**ជាសរុប**, តាមរយៈលទ្ធផលនៃការបូកសរុបគម្រោងចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០១៧, ក្រសួង-ស្ថាប័នចំនួន ៧ ដែលទទួលបានទំហំកញ្ចប់ថវិកាសរុបធំជាងគេ (គិតទាំងចំណាយចរន្ត និងចំណាយមូលធន) តាមលំដាប់ពីធំ ទៅ តូច គឺ៖ ទី១)-ក្រសួងអប់រំ យុវជន និងកីឡា ទទួលបាននូវគម្រោងចំណាយ ២ ៧៤០ ៥០២ លានរៀល, សមមូលប្រមាណ ៦៧៧ លានដុល្លារអាមេរិក, ត្រូវជា ៣,០៨% នៃ ផសស, ស្មើនឹង ១២,៩៦% នៃចំណាយថវិការដ្ឋសរុប; ទី២)-ក្រសួងសាធារណការ និងដឹកជញ្ជូន ទទួលបាននូវគម្រោងចំណាយ ២ ៤១១ ១៤៤ លានរៀល, សមមូលប្រមាណ ៥៩៥ លានដុល្លារអាមេរិក, ត្រូវជា ២,៧១% នៃ ផសស, ស្មើនឹង ១១,៤០% នៃចំណាយថវិការដ្ឋសរុប; ទី៣)-ក្រសួងការពារជាតិ ទទួលបាននូវគម្រោងចំណាយ ១ ៨៥៧ ៥៧៥ លានរៀល, សមមូលប្រមាណ ៤៥៩ លានដុល្លារអាមេរិក, ត្រូវជា ២,០៩% នៃ ផសស, ស្មើនឹង ៨,៧៨% នៃចំណាយថវិការដ្ឋសរុប; ទី៤)-ក្រសួងសុខាភិបាល ទទួលបាននូវគម្រោងចំណាយ ១ ៦៩៧ ៩១១ លានរៀល, សមមូលប្រមាណ ៤១៩ លានដុល្លារអាមេរិក, ត្រូវជា ១,៩១% នៃ ផសស, ស្មើនឹង ៨,០៣% នៃចំណាយថវិការដ្ឋសរុប; ទី៥)- ក្រសួងមហាផ្ទៃ ទទួលបាននូវគម្រោងចំណាយ ១ ៤៦០ ៩៥៤ លានរៀល, សមមូលប្រមាណ ៣៦១ លានដុល្លារអាមេរិក, ត្រូវជា ១,៦៤% នៃ ផសស, ស្មើនឹង ៦,៩១% នៃចំណាយថវិការដ្ឋសរុប; ទី៦)-ក្រសួងធនធានទឹកនិងឧតុនិយម ទទួលបាននូវគម្រោងចំណាយ ១ ០១៨ ៤៦៤ លានរៀល, សមមូលប្រមាណ ២៥១ លានដុល្លារអាមេរិក, ត្រូវជា ១,១៤% នៃ ផសស, ស្មើនឹង ៤,៨១% នៃចំណាយថវិការដ្ឋសរុប; និង ទី៧)-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបាននូវគម្រោងចំណាយ ៧៥៩ ៥៨២ លានរៀល,

សមមូលប្រមាណ ១៨៨ លាន ដុល្លារអាមេរិក, ត្រូវជា ០,៨៥% នៃ ផសស, ស្មើនឹង ៣,៥៩% នៃចំណាយថវិការដ្ឋសរុប ។

## V - អំពីគម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៧

**គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក និង ឃុំ-សង្កាត់** មាន ឱនភាពថវិកាចំនួន ៦៣៨ ១៨៦ លានរៀល, សមមូលប្រមាណ ១៥៨ លានដុល្លារអាមេរិក ហើយនឹងត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ ដែល**ការឧបត្ថម្ភនេះមានកំណើន ២៤,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៦, ត្រូវជា ០,៧២% នៃ ផសស ។**

ត្រង់នេះ ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា អាទិភាពចំណាយ ត្រូវបានផ្តល់ជាពិសេស ដល់ការតម្លើងប្រាក់បៀវត្ស ជូនដល់ក្រុមប្រឹក្សារាជធានី-ខេត្ត, ក្រុង-ស្រុក-ខណ្ឌ, ឃុំ-សង្កាត់ និង មន្ត្រីភូមិ [ដោយចាប់ពីខែមេសា ឆ្នាំ ២០១៧ ទៅ នឹងមានស្ថានភាពដូចខាងក្រោម៖

- ប្រាក់ឧបត្ថម្ភប្រធានក្រុមប្រឹក្សារាជធានី-ខេត្ត នឹងត្រូវបានដំឡើងពី ១ ០៩០ ០០០ រៀល ដល់ ១ ២១០ ០០០ រៀល, ហើយប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត នឹងត្រូវបានដំឡើងពី ៨៧០ ០០០ រៀល ដល់ ៩៧០ ០០០ រៀល;
- ប្រាក់ឧបត្ថម្ភប្រធានក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ នឹងត្រូវបានដំឡើងពី ៨១០ ០០០ រៀល ដល់ ៩៣៥ ០០០ រៀល, ហើយប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ នឹងត្រូវបានដំឡើង ពី ៦៥០ ០០០ រៀល ដល់ ៧៥០ ០០០ រៀល;
- ប្រាក់ឧបត្ថម្ភមេឃុំ-ចៅសង្កាត់ នឹងត្រូវបានដំឡើងពី ៧៥០ ០០០ រៀល ដល់ ៨៨០ ០០០ រៀល, ប្រាក់ឧបត្ថម្ភជំទប់ទី១ ទី ២ ចៅសង្កាត់រងទី១ ទី២ នឹងត្រូវ ដំឡើង ពី ៥៥០ ០០០ រៀល ដល់ ៦៥០ ០០០ រៀល ហើយប្រាក់ឧបត្ថម្ភ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ នឹងត្រូវបានដំឡើងពី ៤៨០ ០០០ រៀល ដល់ ៥៧០ ០០០ រៀល;
- ប្រាក់ឧបត្ថម្ភប្រធានភូមិ នឹងត្រូវបានដំឡើងពី ២០០ ០០០ រៀល ដល់ ២២៥ ០០០ រៀល, ប្រាក់ឧបត្ថម្ភជំនួយការភូមិនឹងត្រូវបានដំឡើងពី ១៦០ ០០០ រៀល ដល់ ១៨០ ០០០ រៀល និង ប្រាក់ឧបត្ថម្ភសមាជិកភូមិនឹងត្រូវបានដំឡើងពី ១៤០ ០០០ រៀល ដល់ ១៦០ ០០០ រៀល]។

## VI - អំពីតុល្យភាពរួមនៃថវិការដ្ឋឆ្នាំ ២០១៧

នៅក្នុងក្របខណ្ឌថវិការដ្ឋ ឬ ថវិកាជាតិខាងលើ (ទាំងថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ) រាជរដ្ឋាភិបាលអាចរក្សាអតិរេកថវិកាចរន្តឱ្យបានក្នុងកម្រិតប្រមាណ ៣,០% នៃ ផសស នៅឆ្នាំ ២០១៧ នេះ ធៀបនឹង ២,៩៩% នៃ ផសស គ្រោងក្នុងច្បាប់ឆ្នាំ ២០១៦។ ជាលទ្ធផល, ឱនភាពថវិកាជាតិសរុបនឹងមានទំហំប្រមាណ -៥,០៩% នៃ ផសស គឺកើនឡើងបន្តិចពីកម្រិតនៃឱនភាពក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០១៦ ដែលស្មើនឹង -៤,៨៨% នៃ ផសស ។ ឱនភាពនេះ ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ ៤,៨១% នៃ ផសស និងមូលនិធិទ្រទ្រង់ថវិកាប្រមាណជា ០,២៨% នៃ ផសស ។

## VII - អំពីបញ្ហាប្រឈមក្នុងការអនុវត្តថវិកាឆ្នាំ ២០១៧

ការអនុវត្តក្របខណ្ឌថវិកាខាងលើ តម្រូវឱ្យរាជរដ្ឋាភិបាលខិតខំដម្ហះនូវការលំបាក និងបញ្ហាប្រឈមមួយចំនួន, ទាំងផ្នែកចំណូល ទាំងផ្នែកចំណាយ។ បញ្ហាប្រឈមចម្បងពាក់ព័ន្ធនឹងផ្នែកចំណូល គឺចំណូលនៅមិនទាន់អាចឆ្លើយតបនឹងទំហំនៃសេចក្តីត្រូវការផ្នែកចំណាយនៅឡើយ ទោះបីជាមានការខិតខំប្រឹងប្រែងក្នុងការកៀរគរចំណូលគួរឱ្យកត់សម្គាល់យ៉ាងណាក្តី។ លើសពីនេះ, ការគ្រោងចំណូលសារពើពន្ធត្រូវបានធ្វើឡើងនៅក្នុងសេណារីយ៉ូសុទិដ្ឋិនិយមកម្រិតខ្ពស់ គួបផ្សំនឹងការធ្លាក់ចុះកាន់តែច្រើននូវចំណូលពន្ធគយ ដោយសារការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ហើយការទប់ស្កាត់អំពើរត់ពន្ធ និងការគេចវេសពន្ធគ្រប់រូបភាព ក៏នៅជួបប្រទះការលំបាកច្រើន។ រីឯផ្នែកចំណាយវិញ គឺសម្ពាធនៃចំណាយ, ទាំងចំណាយបន្ទុកបុគ្គលិក, ទាំងចំណាយក្រៅបន្ទុកបុគ្គលិក, បានកើនឡើងឥតឈប់ឈរ ដោយសារម្ខាង, ការផ្តល់អាទិភាពចាំបាច់បំផុតដល់ការដំឡើងបៀវត្សជូនមន្ត្រីរាជការ ក្នុងគោលដៅឆ្ពោះទៅរកបៀវត្សអប្បបរមាជាង ១ លានរៀល នៅឆ្នាំ ២០១៨, និងម្ខាងទៀត, គឺការបង្កើនចំណាយមួយចំនួនដែលមានភាពចាំបាច់ខ្លាំង ដើម្បីសម្រេចបាននូវអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសការអនុវត្តសកម្មភាពកែទម្រង់គ្រប់វិស័យ និងការវិនិយោគទ្រទ្រង់កំណើនសេដ្ឋកិច្ច។

## VIII - អំពីវិធានការក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៧

ដើម្បីដម្ហះបញ្ហាប្រឈម និងហានិភ័យនានាទាំងក្នុងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និងថវិកាដូចបានគូសបញ្ជាក់ខាងលើ ប្រកបដោយប្រសិទ្ធភាព ព្រមទាំងមានលក្ខណៈជាប្រព័ន្ធ និងដើម្បីសម្រេចបានតាមគោលដៅនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧, រាជរដ្ឋាភិបាលបានកំណត់វិធានការដាក់លាក់សម្រាប់ឆ្នាំ ២០១៧ ដូចមានចែងក្នុងអត្ថបទពិស្តារ

នៃសេចក្តីថ្លែងហេតុជូនរដ្ឋសភា ដែលពាក់ព័ន្ធនឹង៖ (១)-វិធានការឆ្លើយតបនឹងផលប៉ះពាល់អវិជ្ជមានពីហានិភ័យខាងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច; (២)- វិធានការពង្រឹង និងកែលម្អគោល-នយោបាយ និងការគ្រប់គ្រងចំណូល; (៣)- វិធានការពង្រឹង និងកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណាយ, ទាំងផ្នែករៀបចំ និង ផ្នែកអនុវត្តថវិកា; និង(៤)- ការជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ ជាពិសេស កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**"ដំណាក់កាលទី៣-ឆ្នាំ២០១៦-២០២០"**, ការអនុវត្តកម្មវិធីការកែទម្រង់រដ្ឋបាលសាធារណៈ, ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## IX - បទប្បញ្ញត្តិស្តីពីពន្ធដារ

ជាមួយគ្នានេះ, នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ក៏បានបញ្ចូលផងដែរនូវ**បទប្បញ្ញត្តិស្តីពីពន្ធដារ** ចំនួន ៣ មាត្រា រួមមាន ការកែសម្រួលវាក្យ-សព្ទ, ការកែសម្រួលមាត្រាមួយចំនួន និង ការកែសម្រួលការលើកលែងនិងអនុគ្រោះពន្ធប្រថាប់ត្រា ក្នុងគោលបំណងធានាប្រសិទ្ធភាពក្នុងការជំរុញកៀរគរចំណូលឆ្នាំ ២០១៧ ឱ្យទទួលបានលទ្ធផលតាមគោលដៅដែលបានគ្រោងទុក ក៏ដូចជាការបន្តកែលម្អគោលនយោបាយសារពើពន្ធ ជាពិសេស នីតិវិធីក្នុងការប្រមូលពន្ធមួយចំនួនឱ្យបានប្រព្រឹត្តទៅដោយស៊ីសង្វាក់, ប្រទាក់ក្រឡា, រលូន, មានសមធម៌, ធានាបាននូវយុត្តិធម៌សង្គម, តម្លាភាព, ប្រសិទ្ធភាព, គណនេយ្យភាព និងសង្គតិភាព នៅក្នុងបរិការណ៍សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក និងដើម្បីលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការ និងកម្មករនិយោជិត ក៏ដូចជាបន្ធូបន្ថយពន្ធដល់អាជីវកម្មតូចតាច។ ខ្ញុំបាទសូមមិនអធិប្បាយលម្អិតលើបណ្តាសំណើកែ-សម្រួលបទប្បញ្ញត្តិស្តីពីពន្ធដារនោះទេ ក៏ប៉ុន្តែ, សូមអនុញ្ញាតគូសរំលេចចំណុចសំខាន់ៗមួយចំនួនដូចតទៅ៖

**ទី១- ធ្វើការកែសម្រួលកម្រិតអប្បរមានៃប្រាក់ចំណូលជាប់ពន្ធសម្រាប់រូបវន្តបុគ្គល ឬសហគ្រាសឯកបុគ្គល** គឺដើម្បីឱ្យមានសង្គតិភាពនៅក្នុងការអនុវត្តពន្ធលើប្រាក់បៀវត្សដែលត្រូវបានកែប្រែ ព្រមទាំងលើកទឹកចិត្តដល់សហគ្រាសជាអ្នកជាប់ពន្ធតូច ដែលភាគច្រើនប្រកបអាជីវកម្មជាលក្ខណៈគ្រួសារ។

**ទី២- ធ្វើការកែសម្រួលមាត្រា ២៤ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ**, គឺដើម្បីលើកទឹកចិត្តដល់អ្នកជាប់ពន្ធដែលកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវ ឱ្យរួចផុតពីកាតព្វកិច្ចបង់ប្រាក់ពន្ធអប្បបរមា ក៏ដូចជាដើម្បីលើកទឹកចិត្ត និងជំរុញឱ្យអ្នកជាប់ពន្ធទាំងអស់គោរពប្រតិបត្តិឱ្យបានសមស្រប

ទៅតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្មជាធរមាន ដែលនាំមកនូវតម្លាភាព និងភាពប្រកួត-ប្រជែងដោយស្មើភាព ព្រមទាំងក្នុងគោលដៅកៀរគរចំណូលពន្ធទៅថ្ងៃអនាគតផងដែរ។

**ទី៣- ធ្វើការកែសម្រួលមាត្រា ៤៧ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ គឺដើម្បីដំឡើងកម្រិតអប្បបរ-មានៃប្រាក់បៀវត្សជាប់ពន្ធឱ្យឡើងដល់ ១ ០០០ ០០០ រៀល** ដើម្បីផ្តល់ការលើកទឹកចិត្ត និងលើកកម្ពស់ជីវភាពដល់មន្ត្រីរាជការ ពិសេសគ្រូបង្រៀន និង គ្រូពេទ្យ ព្រមទាំងកម្មករនិយោជិត ដែលមានប្រាក់បៀវត្សទាប។ **ប្រការនេះ នឹងផ្តល់ជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅគ្រប់ៗគ្នា ទាំងសម្រាប់មន្ត្រីរាជការ និងទាំងកម្មករនិយោជិតគ្រប់ប្រភេទ ក៏ដូចជាចូលរួមចំណែកលើកកម្ពស់សេវាអប់រំ និង សុខាភិបាលផងដែរ។**

**ទី៤- ធ្វើការកែសម្រួលមាត្រា ៥៧ នៃច្បាប់ស្តីពីសារពើពន្ធ** ដើម្បីបន្ថែមនូវការផ្គត់ផ្គង់មិនជាប់អាករលើតម្លៃបន្ថែមចំនួន ៤ មុខសញ្ញាបន្ថែមទៀត ក្នុងគោលដៅបន្តលើកកម្ពស់ជីវភាពរស់នៅនិងសុខមាលភាពរបស់ប្រជាពលរដ្ឋ ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងពេលកន្លងមក ដែលរួមមាន៖ (១)-សេវាសិក្សាអប់រំ, (២)-ថាមពលអគ្គិសនី និងទឹកស្អាត, (៣)-ផលិតផលកសិកម្មមិនទាន់កែច្នៃ និង (៤)-សេវាប្រមូលឬសម្អាតកាកសំណល់រឹង-រាវ។

**ទី៥- ធ្វើការកែប្រែមាត្រា ១៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣** ដើម្បីផ្តល់ការលើកលែង និងអនុគ្រោះពន្ធប្រថាប់ត្រា តាមការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងពេលកន្លងមក : (១)- លើកលែងពន្ធប្រថាប់ត្រា ចំពោះការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនៈទ្រព្យក្នុងវង្សញាតិ និងការទទួលកម្មសិទ្ធិទោចក្រយានយន្ត, ត្រីចក្រយានយន្តគ្រប់ប្រភេទ, ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ សេះ ដើម្បីបំពេញសំណូមពរដ៏ទទូចរបស់ប្រជាពលរដ្ឋផង និងដើម្បីចូលរួមចំណែកលើកកម្ពស់ជីវភាព និង កាត់បន្ថយចំណាយរបស់ប្រជាពលរដ្ឋផង និង (២)- ផ្តល់ការ-អនុគ្រោះពន្ធប្រថាប់ត្រា ចំពោះការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងវង្សញាតិ ដោយយោងទៅលើសេចក្តីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋ។

ខ្ញុំបាទសុំយកឱកាសនេះ សូមគូសបញ្ជាក់បន្ថែមជូនអង្គសភាទាំងមូលជ្រាបថា វិធានការផ្នែកពន្ធដារខាងលើនេះ គឺត្រូវបានរៀបចំឡើងក្រោមការចង្អុលបង្ហាញ និងណែនាំដោយផ្ទាល់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលសម្តេចតែងតែយកចិត្តទុកដាក់ខ្ពស់ដល់ជីវភាពរស់នៅរបស់មន្ត្រីរាជការគ្រប់ប្រភេទ និងជីវភាពរស់នៅ និងសុខមាលភាពរបស់ប្រជាពលរដ្ឋទូទៅគ្រប់ៗគ្នា។

## X- សេចក្តីសន្និដ្ឋាន

ទោះបីជាត្រូវបន្តជួបប្រទះនឹងបញ្ហាប្រឈម, ការស្មុគស្មាញ និងមានហានិភ័យ ព្រមទាំងនៅមានចំណុចខ្វះខាតមួយចំនួនទៀតក្តី, ក៏ថវិកាឆ្នាំ ២០១៧ ឆ្លុះបញ្ចាំងពីការបង្កើនជាសារវន្តនូវប្រសិទ្ធភាពនៃការរៀបចំ និងការវិភាជថវិកាក្នុងការឆ្លើយតបទៅនឹងអាទិភាពគោល-នយោបាយសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា ជា-ពិសេស ដើម្បីជំរុញការបញ្ចេញលទ្ធផលជាក់ស្តែងជូនប្រជាជន។

សរុបមក, ថវិកាឆ្នាំ ២០១៧ អាចប្រសិទ្ធនាមបានថាជា "**ថវិកានៃការពួតផ្តុំកម្លាំង និងធនធាន និង សម្រួចវិធានការគោលនយោបាយ ដើម្បីសម្រេចឱ្យខាងតែបាននូវសមិទ្ធផលសំខាន់ៗដែលត្រូវបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងសភាពស្មុគស្មាញនៃបរិការណ៍សេដ្ឋកិច្ចតំបន់ និងពិភពលោក ដើម្បីទ្រទ្រង់នូវដំណើរការផ្លាស់ប្តូរមួយប្រកបដោយភាពប្រាកដនិយម ឆ្ពោះទៅរកការអភិវឌ្ឍ ប្រកបដោយគុណភាព និងចីរភាព**"។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេចអគ្គមហាពញាចក្រី និងអង្គសភាទាំងមូល មេត្តាពិនិត្យនិងផ្តល់ការអនុម័តលើសេចក្តីព្រាងច**្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់-គ្រងឆ្នាំ២០១៧** ដោយអនុគ្រោះ។

*សូមអរគុណ !*